Safe retrieval & Disposal of needles and syringes – Khmer

# សុវត្ថិភាពនៃការរើសយកមកវិញ ហើយនិងការបោះចោលម្ជុលនិងប្រដាប់ចាក់ថ្នាំ

ខែកញ្ញា ២០០៣



*គ្រោះថ្នាក់នៃការមានមេរោគ ហិចអៃវី (មេរោគវីរីស៍ដែលបណ្តាលរោគអេដស៍) ឬមេរោគនៅក្នុងឈាមឯទៀត ដោយសារការចាក់ថ្នាំខ្លួនឯងដោយម្ជុលនិងប្រដាប់ចាក់ថ្នាំ មានតិចតួចណាស់ ។*

ធ្វើអ្វីទៅ ប្រសិនបើលោកអ្នកឃើញម្ជុលនិងប្រដាប់ចាក់ថ្នាំដែលគេបានបោះចោលនោះ ។

ប្រសិនបើលោកអ្នកមិនចង់យកម្ជុលនិងប្រដាប់ចាក់ថ្នាំចោលដោយខ្លួនឯងទេ, ឬប្រសិនបើទីកន្លែងមិនសមរម្យទេ, សូមទាក់ទងនឹងទូរស័ព្ទជំនួយ២៤ម៉ោងខាងការបោះចោល ដើម្បីរកពត៌មានបន្ថែម ឬរៀបចំឲ្យគេមកយកវាទៅបោះចោល ។

ទូរស័ព្ទជំនួយខាងការបោះចោលគឺ

១៨០០ ៥៥២ ៣៥៥

ឬ

ប្រសិនបើលោកអ្នកយកវាចេញដោយខ្លួនឯង៖

- សូមពាក់ស្រោមដៃកៅស៊ូ ឬផ្លាស្ទិកសំរាប់ការពារ ។
  ស្រោមដៃក្រាស់ៗ, ដូចជាស្រោមដៃសំរាប់សួនច្បារ, ធ្វើឲ្យមានការលំបាកនឹងរើសម្ជុលនិងប្រដាប់ចាក់ថ្នាំ ។
- សូមយកធុងដែលគេអនុញ្ញាតសំរាប់បោះចោលហើយនិងគំរបទៅដល់ទីកន្លែង ។ គេអាចរកបានធុងទាំងនេះពីកម្មវិធីនៃម្ជុលនិងប្រដាប់ចាក់ថ្នាំ និងនៅតាមសាលាសង្កាត់ជាច្រើន ។
  ប្រសិនបើលោកអ្នកមិនមានធុងដូចនេះទេ, សូមប្រើធុងផ្លាស្ទិករឹងៗ ដូចជាសំបកដបទឹកសាប៊ូទទេ ។ សូមកុំប្រើដបធ្វើអំពីកែវ, ព្រោះវាអាចបែកបាន ។
- ប្រសិនបើមានការលំបាកនឹងលូកដៃដល់, សូមរើសដោយប្រយ័ត្ននូវសម្រាម ឬអ្វីៗដែលនៅជុំវិញវាចេញ ដើម្បីឲ្យលោកអ្នកអាចលូកយកវា ។
- ប្រសិនបើមានម្ជុលនិងប្រដាប់ចាក់ថ្នាំច្រើនជាងមួយ, សូមបំបែកវាដោយឡែកដោយប្រើដំបង ឬចុងអំបោស។ សូមធ្វើដោយប្រយ័ត្នប្រយែង ។ ដូច្នេះ ម្ជុលនិងប្រដាប់ចាក់ថ្នាំនិមួយៗអាចឲ្យគេរើសវាមួយម្តងៗ ។
- សូមរើសម្ជុលនិងប្រដាប់ចាក់ថ្នាំពីខាងចុងបំពង់(ខាងចុងផ្លាស្ទិក) សូមកុំរើសពីចុងម្ជុល ។ សូមធ្វើឲ្យប្រាកដថាមុខម្ជុលបែរចេញពីលោកអ្នក ។
- សូមកុំគ្រប ម្ជុលនិងប្រដាប់ចាក់ថ្នាំ, ទោះបីគំរបនោះត្រូវបានគេបោះចោលហើយក៏ដោយ ។
- សូមដាក់ម្ជុលនិងប្រដាប់ចាក់ថ្នាំទៅក្នុងធុងដោយដាក់ម្ជុលទៅមុន ។ ធុងគួរតែដាក់នៅលើផ្ទៃនឹង ហើយសូមកុំកាន់ដោយដៃ ។
- សូមបិទគំរបធុងឲ្យបានតឹងបំផុត ។
- សូមយកស្រោមដៃទៅដាក់ក្នុងថង់ផ្លាស្ទិក ។ សូមចងម៉ាត់ថង់នឹងចំណង ហើយយកវាទៅដាក់នៅក្នុងធុងសំរាម ។
- សូមលាងដៃលោកអ្នកនឹងសាប៊ូហើយនិងទឹក ។
- ដើម្បីយកធុងទៅចោល សូមយកទៅឲ្យកម្មវិធីនៃម្ជុលនិងប្រដាប់ចាក់ថ្នាំនៅតាមតំបន់, ការិយាល័យសាលាសង្កាត់នៃតំបន់លោកអ្នក ឬទាក់ទងនឹងទូរស័ព្ទជំនួយខាងការបោះចោលសំរាប់រកឱវាទបន្ថែមទៀត ។ សូមកុំបោះចោលម្ជុលនិងប្រដាប់ចាក់ថ្នាំទៅក្នុងធុងសំរាម, បំពង់បង្ហូរទឹក ឬបង្គន់ ។

ធ្វើអ្វីទៅ ប្រសិនបើលោកអ្នកត្រូវរងរបួសដោយម្ជុលមុត

ប្រសិនបើលោកអ្នកមុតនឹងម្ជុលនិងប្រដាប់ចាក់ថ្នាំដែលគេបោះចោល(ជារឿយៗគេសន្មត់ថា ការរងរបួសដោយម្ជុល)នោះ, មានវិធានការមួយចំនួនដែលត្រូវគេចាត់ការដូចតទៅនេះ ៖

- សូមបង្ហូរទឹកនៅលើកន្លែងរបួស ។
- សូមលាងមុខរបួសដោយសាប៊ូនិងទឹកក្តៅឲ្យបានស្អាតល្អ ។
- សូមលាបថ្នាំ អង្គីសេបទិក នៅលើមុខរបួសដោយបិទបង់របួសមិនជ្រាបទឹកផង ។
- សូមស្វែងរកឱវាទពេទ្យ ដើម្បីប៉ាន់មើលគ្រោះថ្នាក់នៃការរងរបួសហើយនិងរកការព្យាបាលឲ្យបានត្រឹមត្រូវ ។
- ប្រសិនបើគេមិនអាចរើសយកម្ជុលនិងប្រដាប់ចាក់ថ្នាំមកវិញទេ, សូមគូសចំណាំកន្លែងនោះដើម្បីកុំឲ្យអ្នកឯទៀតមានគ្រោះថ្នាក់ ហើយ ទាក់ទងទូរស័ព្ទជំនួយផង ។